# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៦-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១២២ ស្ដីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈ ជូនសពលោកវរសេនីយនឹងឯក អ៊ូ ង៉ម នាយនគរបាលជាតិជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ២១៨

២៩-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១២៣ ស្ដីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប ២១៩

២៩-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១២៤ ស្ដីពី ការបង្កើតគណៈស្ថាបត្យករកម្ពុជា ២២០

២៩-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១២៥ ស្ដីពី ការតែងតាំង លោក **ហេង សំណាង** ជា ឧកញ៉ា ២៣០

៣០-១២-២០១១-ព្រះរាជក្រឹត្យ នស/រកត/១២១១/១១២៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះអាជ្ញាធរដែនដី មន្ត្រីរាជការ ស្ថាបត្យករ ចំនួន ០៩ រូប ២៣១

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

០៤-០១-២០១២-អនុក្រឹត្យលេខ ០១ អនក្រ.បក ស្ដីពី ការកាត់ចេញពីផែនទីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និង ការចាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដី ដែលបានដកហូតដោយដីការបស់សាលាខេត្តក្រចេះ កាលពីឆ្នាំ ២០០៦ ២៣២

០៤-០១-២០១២-អនុក្រឹត្យលេខ ០២ អនក្រ.បក ស្ដីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨៣៥ ហិកតា និង១.៨០០ ម៉ែត្រក្រឡា ស្ថិតនៅក្នុងព្រៃការពារ និងអភិរក្ស ជីវចំរុះ " សីមា " ក្នុងភូមិអណ្តូងក្រឡឹង ឃុំសែនមនោរម្យ ស្រុកអូរាំង ខេត្តមណ្ឌលគិរី ២៣៦

០៣-០១-២០១២-អនុក្រឹត្យលេខ ០១ អនក្រ.តត ស្ដីពី ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ ២៣៩

០៣-០១-២០១២-អនុក្រឹត្យលេខ ០២ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ២៤០

០៣-០១-២០១២-អនុក្រឹត្យលេខ ០៣ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៤១

០៣-០១-២០១២-អនុក្រឹត្យលេខ ០៤ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ២៤៤

០៣-០១-២០១២-អនុក្រឹត្យលេខ ០៥ អនក្រ.តត ស្ដីពី ការតែងតាំងសមាសភាពគណៈកម្មការបណ្ឌិត្យសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់ ២៤៧

០៤-០១-២០១២ -អនុក្រឹត្យលេខ ០៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២៤៩
០៦-០១-២០១២ -អនុក្រឹត្យលេខ ០៧ អនក្រ.តត ស្តីពី ការតែងតាំងមុខងារ នាយទាហាន ២៥០
០៦-០១-២០១២ -អនុក្រឹត្យលេខ ០៨ អនក្រ.តត ស្តីពី ការដំឡើងថ្នាក់ មន្ត្រីរាជការ ២៥១
០៦-០១-២០១២ -អនុក្រឹត្យលេខ ០៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២៥៤
០៦-០១-២០១២ -អនុក្រឹត្យលេខ ១០ អនក្រ.តត ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៥៥
០៦-០១-២០១២ -អនុក្រឹត្យលេខ ១១ អនក្រ.តត ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ២៥៧
១០-០១-២០១២ -អនុក្រឹត្យលេខ ១២ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតកម្ពុជា " កម្ពុជា ឡៃហ្វ " អាណត្តិ ទី ១ ២៥៩
១០-០១-២០១២ -អនុក្រឹត្យលេខ ១៣ អនក្រ.តត ស្តីពី ការតែងតាំងអគ្គនាយក នៃក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតកម្ពុជា " កម្ពុជា ឡៃហ្វ " អាណត្តិ ទី ១ ២៦១

## ២-សេចក្តីសម្រេច

០៦-០១-២០១២ -សេចក្តីសម្រេចលេខ ០១ សសរ ស្តីពី ការបង្កើតក្រុមការងាររួមក្នុងការពិភាក្សាអនុវត្តដីកាបង្គាប់របស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ) ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១១ ២៦៣

## III-ការិយាល័យក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៨-១១-២០១០-លិខិតបញ្ជាក់លេខ ៥២៧១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ព្រេសីស ខែរ អ៊ិនធើណេសិនណល លីមីធីត** ២៦៦
១៨-១១-២០១០-លិខិតបញ្ជាក់លេខ ៥២៧២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាន ម៉ាឌី ខេ អ៊ិនវេសមេន** ២៦៨
១៨-១១-២០១០-លិខិតបញ្ជាក់លេខ ៥២៨១ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ព្រៃរី ផេស៊ីហ្វិក ម៉ាញូនីខ (ខេមបូឌា) (តី តី អិម ស៊ី)** ២៧០
១៨-១១-២០១០-លិខិតបញ្ជាក់លេខ ៥២៨៥ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ភ្នំ សុខណ្ណភូមិ** ២៧២

១៩-១១-២០១០ -លិខិតបញ្ជាក់លេខ ៥២៩១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល.អ.អេច.ជី(ខេមបូឌា) ឌីវេឡុបមេន** ២៧៤

១៩-១១-២០១០ -លិខិតបញ្ជាក់លេខ ៥២៩៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រ៉ូយ៉ាល់ ត្រាយអាំ ខន ស្ត្រាក់សិន & ដេខ័រេដ** ២៧៦

១៩-១១-២០១០ -លិខិតបញ្ជាក់លេខ ៥២៩៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី.ស៊ី.អេស.អ៊ីមផត អិចផត** ២៧៨

១៩-១១-២០១០ -លិខិតបញ្ជាក់លេខ ៥២៩៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេម៉ាស៊ី អេនធើប្រាយ** ២៨០

# ព្រះរាជក្រឹត្យ

នស/រកត/១២១១/១១៧២

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៣៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈជូនសពលោកវរសេនីយ៍ឯក **អ៊ូ ឯម** អត្តលេខ ០១៦៨៩ នាយនគរបាលជាតិជាន់ខ្ពស់ ក្រសួងមហាផ្ទៃ។

**មាត្រា ២** : សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល. ១១១២. ១១៤៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១១

លេខ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១១
[illegible] ទីស្ដីការគណៈរដ្ឋមន្ត្រី / រាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១១/១១៧៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប÷

១- ឧត្តមសេនីយ៍ត្រី **មួង សុភា** អត្តលេខ ០០៤៣២៩

២- ឧត្តមសេនីយ៍ត្រី **មាស សុទន្តា** អត្តលេខ ០០៤៣៣០

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារទ.១១១៧.១១៤៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១១

លេខ ១១៩៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១១
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១១/១១៧៤

## ស្តីពី

## ការបង្កើតគណៈស្ថាបត្យករកម្ពុជា

---

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១១

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈស្ថាបត្យករកម្ពុជាដែលសរសេរជាអក្សរកាត់ថា **គ.ស.ក.** និងដែលមានគោលបំណងប្រមូលផ្តុំនិងគ្រប់គ្រងស្ថាបត្យករដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលើកកម្ពស់វិជ្ជាជីវៈ គុណភាពស្នាដៃរបស់ស្ថាបត្យករ និងកិត្យានុភាពនៃស្ថាបត្យកម្មកម្ពុជា។

**មាត្រា ២.-**

ព្រះរាជក្រឹត្យនេះមានគោលដៅដូចតទៅៈ

- រួមចំណែករៀបចំវិជ្ជាជីវៈស្ថាបត្យកម្មឲ្យកាន់តែល្អប្រសើរ ដើម្បីការពារកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ថាបត្យករ
- រួមចំណែកថែរក្សា ការពារ អភិវឌ្ឍស្ថាបត្យកម្មខ្មែរ និងលើកកម្ពស់អត្តសញ្ញាណជាតិ
- ពង្រឹងនិងលើកកម្ពស់សមត្ថភាពនិងគុណភាពបន្ថែមដល់ស្ថាបត្យករដែលប្រកបមុខរបរអាជីវកម្ម ដោយគោរពខ្ជាប់ខ្ជួននូវក្រមសីលធម៌
- ធានាឲ្យបានការប្រកបវិជ្ជាជីវៈស្ថាបត្យកម្មមានគុណភាព ប្រសិទ្ធភាព សុវត្ថិភាព ស្ថិរភាព និងមានការទទួលខុសត្រូវខ្ពស់ក្នុងការការពារទេសភាពធម្មជាតិនិងបេតិកភណ្ឌជាតិ
- ពង្រឹងនិងបើកទូលាយទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ ព្រមទាំងធ្វើសមាហរណកម្មស្ថាបត្យកម្មជាតិចូលក្នុងពិភពលោកនិងក្នុងតំបន់ ជាពិសេសក្នុងសមាគមជាមួយបណ្តាប្រទេសអាស៊ាន
- ទទួលស្គាល់ទេពកោសល្យរបស់ស្ថាបត្យករកម្ពុជា ដើម្បីឲ្យមានគោរមងារជាស្ថាបត្យករជាតិនិងអន្តរជាតិ
- រួមចំណែកក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈស្ថាបត្យកម្ម ដើម្បីអភិវឌ្ឍធនធានមនុស្សឲ្យស្របតាមតម្រូវការសង្គមជាតិ តម្រូវការតំបន់ និងតម្រូវការពិភពលោក
- លើកទឹកចិត្តស្ថាបត្យករដែលបង្កើតទស្សនៈស្ថាបត្យកម្មថ្មីៗនិងស្ថាបត្យកម្ម ដែលមានលក្ខណៈជាអត្តសញ្ញាណជាតិគួបផ្សំនឹងលក្ខណៈទំនើប។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះស្ថាបត្យករខ្មែរនិងស្ថាបត្យករបរទេសដែលបានចុះឈ្មោះក្នុងបញ្ជី គ.ស.ក.។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងព្រះរាជក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- **ស្ថាបត្យកម្ម** សំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃការបង្កើតរចនាសម្ព័ន្ធអគារនិងការសាងសង់ទាំងក្នុងនិងក្រៅនៃសំណង់ផ្សេងៗ ស្របតាមលក្ខណៈបច្ចេកទេសនិងតាមសំណុំសោភណភាពដែលបានគ្រោងទុក ដោយឆ្លុះបញ្ចាំងពីអត្តសញ្ញាណជាតិ សង្គម និងការការពារបរិស្ថាន។
- **ស្ថាបត្យករ** សំដៅដល់រូបវន្តបុគ្គលខ្មែរនិងបរទេសដែលបានបញ្ចប់ការសិក្សាជំនាញស្ថាបត្យកម្មដោយជោគជ័យ តាមគ្រឹះស្ថានឧត្តមសិក្សានានានៅព្រះរាជាណាចក្រកម្ពុជាឬនៅបរទេស ហើយមានការទទួលស្គាល់សញ្ញាបត្រស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។
- **ស្ថាបត្យករចុះបញ្ជី** សំដៅដល់ស្ថាបត្យករខ្មែរនិងស្ថាបត្យករបរទេសដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** ហើយមិនទាន់បានបំពេញលក្ខខណ្ឌដើម្បីក្លាយជាស្ថាបត្យករ **គ.ស.ក.**។
- **ស្ថាបត្យករគ.ស.ក.** សំដៅដល់ស្ថាបត្យករខ្មែរនិងស្ថាបត្យករបរទេសដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** ហើយបានបំពេញលក្ខខណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សា **គ.ស.ក.**និងស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។
- **ស្ថាបត្យករអាស៊ាន** សំដៅដល់រូបវន្តបុគ្គលដែលមានសញ្ជាតិក្នុងប្រទេសជាសមាជិកអាស៊ាននិងបានបំពេញលក្ខខណ្ឌត្រឹមត្រូវស្របតាមកិច្ចព្រមព្រៀងនៃការទទួលស្គាល់គ្នាទៅវិញទៅមកលើសេវាកម្មស្ថាបត្យកម្មរបស់អាស៊ានក្រោមការត្រួតពិនិត្យនិងការវាយតម្លៃរបស់ក្រុមប្រឹក្សាស្ថាបត្យករអាស៊ាន។
- **វិជ្ជាជីវៈស្ថាបត្យកម្ម** សំដៅដល់រាល់ការងារពាក់ព័ន្ធនឹងការសិក្សា ការរៀបចំនិងការអនុវត្តគម្រោងប្លង់ស្ថាបត្យកម្ម និងលិខិតបទដ្ឋានបច្ចេកទេសទាំងឡាយដែលទាក់ទងនឹងការងារស្ថាបត្យកម្ម។

## ជំពូកទី២
## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈស្ថាបត្យករកម្ពុជា
### ផ្នែកទី១
### ប្រធានកិត្តិយសនៃគណៈស្ថាបត្យករកម្ពុជា

**មាត្រា ៥.-**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយសនៃ **គ.ស.ក.**។

**មាត្រា ៦.-**

ប្រធានកិត្តិយសនៃ **គ.ស.ក.** ជាអធិបតីក្នុងមហាសន្និបាត **គ.ស.ក.** និងផ្តល់អនុសាសន៍ណែនាំដល់ **គ.ស.ក.**។

ក្នុងករណីចាំបាច់ ប្រធានកិត្តិយសនៃ **គ.ស.ក.**អាចប្រគល់ភារកិច្ចជូនឥស្សរជនណាមួយធ្វើជាតំណាងដើម្បីធ្វើជាអធិបតីក្នុងមហាសន្និបាត **គ.ស.ក.** ។

## ផ្នែកទី២

## ក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា

**មាត្រា ៧.-**

ក្រុមប្រឹក្សា **គ.ស.ក.** មានសមាសភាពដូចតទៅៈ

- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាន
- ឥស្សរជនជាន់ខ្ពស់នៃស្ថាប័នជាតិឬឥស្សរជនកម្ពុជា ដែលមានបទពិសោធខាងវិស័យស្ថាបត្យកម្ម អនុប្រធាន
- តំណាងក្រសួង ស្ថាប័នដែលពាក់ព័ន្ធនឹងវិស័យស្ថាបត្យកម្ម សមាជិក
- តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃរាជរដ្ឋាភិបាល សមាជិក
- តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សមាជិក
- តំណាងសភាពាណិជ្ជកម្មកម្ពុជា សមាជិក
- អគ្គលេខាធិការ **គ.ស.ក.** សមាជិកអចិន្ត្រៃយ៍

សមាសភាពក្រុមប្រឹក្សា **គ.ស.ក.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

**មាត្រា ៨.-**

ក្រុមប្រឹក្សា **គ.ស.ក.** មានសិទ្ធិទាក់ទងនិងអញ្ជើញតំណាងក្រសួង ស្ថាប័ននានាដែលពុំមានចែងក្នុងមាត្រា៧ខាងលើ សមាគម អង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន អង្គការអន្តរជាតិ និងតំណាងប្រទេសនានាតាមការចាំបាច់ ដើម្បីចូលរួមប្រជុំផ្តល់យោបល់ឬធ្វើជាអ្នកសង្កេតការណ៍។

**មាត្រា ៩.-**

ក្រុមប្រឹក្សា **គ.ស.ក.** មានភារកិច្ចដូចតទៅៈ

- អនុម័តគោលនយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាព បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌ស្ថាបត្យករ
- អនុម័តថវិកាប្រចាំឆ្នាំរបស់ **គ.ស.ក.**
- តាមដាននិងត្រួតពិនិត្យដំណើរការការងាររបស់ **គ.ស.ក.**
- ផ្តល់យោបល់ដល់អគ្គលេខាធិការដ្ឋានអំពីការងារចាំបាច់
- សម្របសម្រួលនិងដោះស្រាយវិវាទផ្សេងៗរបស់ **គ.ស.ក.**
- ផ្តល់យោបល់ក្នុងការចុះបញ្ជីស្ថាបត្យករ ការលើកទឹកចិត្ត និងការដាក់វិន័យ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ក្រះបរមរាជវាំង

**មាត្រា ១០.-**

ក្រុមប្រឹក្សា គ.ស.ក. ត្រូវប្រជុំយ៉ាងតិចរៀងរាល់១(មួយ)ឆ្នាំម្តង។ ក្នុងករណីចាំបាច់ ប្រធានក្រុមប្រឹក្សា គ.ស.ក. អាចកោះប្រជុំជាវិសាមញ្ញបាន។

## ផ្នែកទី៣

## អគ្គលេខាធិការដ្ឋាន

**មាត្រា ១១.-**

គ.ស.ក. ត្រូវមានអគ្គលេខាធិការដ្ឋានមួយដែលមានតួនាទីជាអង្គភាពប្រតិបត្តិនិងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាព បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌ស្ថាបត្យករដែលអនុម័តដោយក្រុមប្រឹក្សា គ.ស.ក.
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ដំណើរការ គ.ស.ក.
- ធានានិរន្តរភាពការងាររបស់អគ្គលេខាធិការដ្ឋាន
- ផ្សព្វផ្សាយអនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលទាក់ទងនឹងវិស័យស្ថាបត្យកម្មគ្រប់ជំនាញ និងចូលរួមរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយពាក់ព័ន្ធនឹងវិស័យស្ថាបត្យកម្មតាមការអញ្ជើញរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ជួយការពារកម្មសិទ្ធិបញ្ញារបស់ស្ថាបត្យករចុះបញ្ជី
- ពង្រឹងសមត្ថភាពក្នុងការចូលរួមប្រកួតប្រជែងដោយយុត្តិធម៌និងស្មើភាពគ្នារវាងស្ថាបត្យករចុះបញ្ជីកម្ពុជានិងស្ថាបត្យករបរទេស
- ធ្វើសហប្រតិបត្តិការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា គ្រឹះស្ថានឧត្តមសិក្សា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់កម្មវិធីសិក្សាវគ្គបំប៉នជំនាញនិងការអប់រំឧត្តមសិក្សា
- លើកស្ទួយការបណ្តុះបណ្តាលបន្តដល់ស្ថាបត្យករកម្ពុជា ដើម្បីលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈស្ថាបត្យកម្មឲ្យមានការទទួលស្គាល់ក្នុងក្របខ័ណ្ឌអាស៊ាននិងអន្តរជាតិ តាមគោលការណ៍នៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកក្នុងអាស៊ាន
- ពិនិត្យតាមដានការប្រកបវិជ្ជាជីវៈស្ថាបត្យកម្មរបស់ស្ថាបត្យករចុះបញ្ជីស្ថាបត្យករ គ.ស.ក. និងស្ថាបត្យករបរទេស
- ចុះបញ្ជីកំណត់គុណវុឌ្ឍិអាជីពវិជ្ជាជីវៈស្ថាបត្យកម្មរបស់រូបវន្តបុគ្គលឲ្យទៅជាស្ថាបត្យករ គ.ស.ក. និងធានានិរន្តរភាពនៃការចុះបញ្ជីស្ថាបត្យករនៅព្រះរាជាណាចក្រកម្ពុជា

- ជ្រើសរើសនិងវាយតម្លៃលើបេក្ខភាពស្ថាបត្យករ គ.ស.ក. ដើម្បីឲ្យទៅជាស្ថាបត្យករអាស៊ាន
- រៀបចំគុណវុឌ្ឍិជំនាញវិជ្ជាជីវៈនិងក្រមសីលធម៌របស់ស្ថាបត្យករចុះបញ្ជីនិងស្ថាបត្យករ គ.ស.ក. ដោយសហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ
- ធ្វើការត្រួតពិនិត្យលើការអនុវត្តការងាររបស់ស្ថាបត្យករចុះបញ្ជីនិងស្ថាបត្យករ គ.ស.ក. ក្នុងករណីមានទំនាស់ក្នុងការបំពេញវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ គ.ស.ក. ក្នុងកិច្ចប្រជុំប្រចាំឆ្នាំនិងក្រុមប្រឹក្សា គ.ស.ក.
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនដោយក្រុមប្រឹក្សា គ.ស.ក.។

**មាត្រា ១២.-**

អគ្គលេខាធិការដ្ឋាន គ.ស.ក. ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូបអមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់។ អគ្គលេខាធិការមានឋានៈទាបបំផុតស្មើរដ្ឋលេខាធិការ និងអគ្គលេខាធិការរងមានឋានៈទាបបំផុតស្មើអនុរដ្ឋលេខាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គ.ស.ក. ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ១៣.-**

អគ្គលេខាធិការនិងអគ្គលេខាធិការរង គ.ស.ក. ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយមហាសន្និបាត គ.ស.ក. សម្រាប់អាណត្តិ៥(ប្រាំ)ឆ្នាំ។

ស្ថាបត្យករមានសញ្ជាតិខ្មែរដែលអាចឈរឈ្មោះឲ្យមហាសន្និបាត គ.ស.ក. បោះឆ្នោតជាអគ្គលេខាធិការឬអគ្គលេខាធិការរងបាន ត្រូវមានឈ្មោះក្នុងបញ្ជីស្ថាបត្យករ គ.ស.ក. យ៉ាងតិច ៥(ប្រាំ)ឆ្នាំ ហើយមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋណាមួយឡើយ។

**មាត្រា ១៤.-**

ក្នុងករណីដែលអគ្គលេខាធិការឬអគ្គលេខាធិការរងណាម្នាក់ទទួលមរណភាពឬលាឈប់ពីមុខងារក្នុងអាណត្តិរបស់ខ្លួននោះ គ.ស.ក. ត្រូវជ្រើសរើសអ្នកជំនួសដើម្បីបន្តបញ្ចប់អាណត្តិស្របតាមបទបញ្ជាផ្ទៃក្នុង។

**មាត្រា ១៥.-**

គ.ស.ក.មានរូបសញ្ញានិងត្រាដោយឡែករបស់ខ្លួន។

## ផ្នែកទី៤

## ក្រុមប្រឹក្សាគណៈស្ថាបត្យកររាជធានី ខេត្ត

**មាត្រា ១៦.-**

គ.ស.ក. អាចបង្កើតក្រុមប្រឹក្សាគណៈស្ថាបត្យកររាជធានី ខេត្តបាន ក្នុងករណីមានសមាជិកជាស្ថាបត្យករចាប់ពី២០(ម្ភៃ)រូបឡើងទៅ ដែលក្នុងនោះត្រូវមានស្ថាបត្យករ គ.ស.ក. យ៉ាងតិច៥(ប្រាំ)រូប។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាគណៈស្ថាបត្យកររាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា គ.ស.ក.។

## ផ្នែកទី៥
## មហាសន្និបាត

**មាត្រា ១៧.-**

មហាសន្និបាតប្រចាំឆ្នាំរបស់គ.ស.ក. ត្រូវប្រព្រឹត្តទៅតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាគ.ស.ក.។

មហាសន្និបាត គ.ស.ក. ប្រព្រឹត្តទៅ៥(ប្រាំ)ឆ្នាំម្តង ដើម្បីរៀបចំការបោះឆ្នោតជ្រើសរើសអគ្គលេខាធិការនិងអគ្គលេខាធិការរង។

មហាសន្និបាតវិសាមញ្ញអាចប្រព្រឹត្តទៅបានតាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សា គ.ស.ក.ឬតាមការស្នើសុំពីស្ថាបត្យករ គ.ស.ក. យ៉ាងតិចចំនួន៣០(សាមសិប)ភាគរយ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ មុនថ្ងៃប្រជុំដោយមានភ្ជាប់របៀបវារៈមកជាមួយផង។

**មាត្រា ១៨.-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មហាសន្និបាត គ.ស.ក. ដូចមានចែងក្នុងមាត្រា១៧ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង គ.ស.ក.។

## ជំពូកទី៣
## ការប្រកបវិជ្ជាជីវៈស្ថាបត្យកម្ម

**មាត្រា ១៩.-**

ស្ថាបត្យករដែលអាចក្លាយទៅជាស្ថាបត្យករ គ.ស.ក. បានត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បានចុះឈ្មោះក្នុងបញ្ជី គ.ស.ក.
- គ្មានការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈនេះដោយតុលាការ
- បំពេញលក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា គ.ស.ក.។

**មាត្រា ២០.-**

ស្ថាបត្យករដែលបានបំពេញគ្រប់លក្ខខណ្ឌដូចមានចែងក្នុងមាត្រា១៩ខាងលើ ត្រូវទទួលបានវិញ្ញាបនបត្រស្ថាបត្យករ គ.ស.ក.ដែលចេញដោយ គ.ស.ក.។

**មាត្រា ២១.-**

ការប្រកបវិជ្ជាជីវៈស្ថាបត្យកម្ម ត្រូវគោរពតាមក្រមសីលធម៌ស្ថាបត្យករដែលអនុម័តដោយក្រុមប្រឹក្សា គ.ស.ក.។

**មាត្រា ២២.-**

ស្ថាបត្យករបរទេសដែលមានបំណងប្រកបវិជ្ជាជីវៈស្ថាបត្យកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** និងត្រូវគោរពតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២៣.-**

ស្ថាបត្យករខ្មែរនិងស្ថាបត្យករបរទេសដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** នៅព្រះរាជាណាចក្រកម្ពុជាត្រូវបង់ភាគទានប្រចាំឆ្នាំជូន **គ.ស.ក.**។

ភាគទានដែលត្រូវបង់ជូន **គ.ស.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា **គ.ស.ក.**។

**មាត្រា ២៤.-**

ស្ថាបត្យករចុះបញ្ជីនិងស្ថាបត្យករ **គ.ស.ក.** អាចសុំព្យួរឬសុំលាឈប់ពីសមាជិក **គ.ស.ក.** បានតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា **គ.ស.ក.**។

## ជំពូកទី៤
## គោរមងារ

**មាត្រា ២៥.-**

**គ.ស.ក.** អាចថ្វាយឬជូនគោរមងារជាមហាវស្ថាបត្យករជាតិឬវស្ថាបត្យករជាតិចំពោះឥស្សរជនជាន់ខ្ពស់ដែលមានគុណូបការៈក្នុងការដឹកនាំនិងស្ថាបនាជាតិ។

**មាត្រា ២៦.-**

**គ.ស.ក.** អាចផ្តល់គោរមងារជាស្ថាបត្យករជាតិជូនចំពោះស្ថាបត្យករ **គ.ស.ក.** ដែលបានប្រកបវិជ្ជាជីវៈស្ថាបត្យកម្មរយៈពេល១៥(ដប់ប្រាំ)ឆ្នាំឡើងទៅ។

**គ.ស.ក.** អាចផ្តល់គោរមងារជាស្ថាបត្យករកិត្តិយសជូនចំពោះឥស្សរជនឬបុគ្គលទាំងឡាយណាដែលបានឧបត្ថម្ភគាំទ្រផ្នែកថវិកាឬបច្ចេកទេសចំពោះ **គ.ស.ក.** តាមការកំណត់របស់ក្រុមប្រឹក្សា **គ.ស.ក.**។

**មាត្រា ២៧.-**

គោរមងារជាស្ថាបត្យករជាតិអាចត្រូវដកហូតវិញបាន ប្រសិនបើស្ថាបត្យកររូបនោះបានប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌ស្ថាបត្យករ។

## ជំពូកទី៥
## ក្រុមប្រឹក្សាវិន័យ

**មាត្រា ២៨.-**

ក្រុមប្រឹក្សាវិន័យមានសមាសភាពចំនួន៥(ប្រាំ)រូប ដែលត្រូវតែងតាំងឡើងដោយប្រធានក្រុមប្រឹក្សា គ.ស.ក.ក្នុងចំណោមសមាជិកក្រុមប្រឹក្សា **គ.ស.ក.** និងសមាជិកនៃអគ្គលេខាធិការ **គ.ស.ក.**។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការសម្រេចដាក់វិន័យត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង គ.ស.ក.។

**មាត្រា ២៩.-**

ក្រុមប្រឹក្សាវិន័យមានតួនាទី ដូចតទៅ៖

- ទទួលបណ្តឹងតវ៉ាផ្សេងៗពាក់ព័ន្ធនឹងស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.**
- ដោះស្រាយវិវាទទាក់ទងនឹងវិជ្ជាជីវៈរបស់ស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.**
- ដាក់ទណ្ឌកម្មខាងវិន័យដល់ស្ថាបត្យករណាដែលប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌ស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.**។

**មាត្រា ៣០.-**

ស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី **គ.ស.ក.** ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចដាក់ទណ្ឌកម្មរបស់ក្រុមប្រឹក្សាវិន័យ មានសិទ្ធិប្តឹងតវ៉ាទៅប្រធានក្រុមប្រឹក្សា **គ.ស.ក.**។ ប្រធានក្រុមប្រឹក្សា **គ.ស.ក.** ត្រូវចាត់តាំងសមាជិកចំនួន៧(ប្រាំពីរ)រូបផ្សេងទៀតក្រៅពីសមាសភាពក្រុមប្រឹក្សាវិន័យ ដើម្បីពិនិត្យនិងសម្រេចលើបណ្តឹងតវ៉ានោះ។ សេចក្តីសម្រេចចុងក្រោយជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

បែបបទ នីតិវិធីនៃការតវ៉ា និងរយៈពេលនៃការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង **គ.ស.ក.**។

## ជំពូកទី៦
## ទណ្ឌកម្មខាងវិន័យ

**មាត្រា ៣១.-**

ទណ្ឌកម្មខាងវិន័យរួមមាន៖

- ការស្តីបន្ទោស
- ការព្រមាន
- ការព្យួរសិទ្ធិមួយរយៈពេល ដែលមិនអាចលើសពី២(ពីរ)ឆ្នាំ
- ការលុបឈ្មោះចេញពីបញ្ជី **គ.ស.ក.** ឬដកហូតគោរមងារស្ថាបត្យករជាតិ។

ការទទួលទណ្ឌកម្មខាងវិន័យ មិនធ្វើនាំឲ្យបុគ្គលនោះរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណី និងព្រហ្មទណ្ឌឡើយ។

## ជំពូកទី៧
## ប្រភពធនធាន

**មាត្រា ៣២.-**

ប្រភពធនធានរបស់ **គ.ស.ក.** សម្រាប់បំពេញការងាររបស់ខ្លួនបានមកពី៖

- ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- ភាគទានដែលបានពីសមាជិក គ.ស.ក.
- អំណោយនិងវិភាគទានពីដៃគូអភិវឌ្ឍ សហគមអន្តរជាតិ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា
- ចំណូលបានពីសកម្មភាពនានារបស់ គ.ស.ក.
- ជំនួយឥតសំណងផ្សេងៗ។

គ.ស.ក. មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិជំនួយផ្នែកបច្ចេកទេសនិងសម្ភារៈផ្សេងៗទៀតពីប្រភពក្នុងនិងក្រៅប្រទេស សម្រាប់បម្រើការក្នុងការបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៣.-**

ក្នុងអាណត្តិដំបូង អគ្គលេខាធិការនិងអគ្គលេខាធិការរងនៃ គ.ស.ក. ត្រូវតែងតាំងដោយរាជរដ្ឋាភិបាលតាមសំណើរបស់ប្រធានក្រុមប្រឹក្សា គ.ស.ក.។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា ៣៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៥.-**

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១១

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត ១២១១.១១៤៥

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ ០៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០១២
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១១/១១៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**តែងតាំង**

**លោក ហេង សំណាង**

**ជា**

**ឧកញ៉ា**

៣៧៣. ១១១២. ១១៤៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខៈ ០៤ ច.ល

**ថតចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០១២

**អគ្គ[illegible]ការរងទីស្តីការរាជរដ្ឋាភិបាល**

**[illegible]យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១១/ ១១២៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

ចំពោះ

អាជ្ញាធរដែនដី មន្ត្រីរាជការ ស្ថាបត្យករ ចំនួន០៩រូប ដែលមានស្នាដៃល្អខិតខំប្រឹងប្រែងចូលរួមចំណែក ក្នុងការសាងសង់ស្ពានអាកាសស្តុបពេទ្យលោកសង្ឃ រួចរាល់ជាស្ថាពរ នៅពាក់កណ្តាលខែមករា ឆ្នាំ២០១២ ទទួលបានលទ្ធផលល្អប្រសើរ

នូវ

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-លោក នួន សុមេធ
២-លោក សេង រតនៈ

**ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

លោក ឃួង ស្រេង

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :**

១-លោក សាំ ពិសិដ្ឋ
២-លោក ពៅ ម៉េងហៃ
៣-លោក សំ សាមុត
៤-លោក ងួច សំណាង
៥-លោក Lai Long Zhao
៦-លោក រ៉ា បូរីវុឌ្ឍ

លេខរៀងទី១ ចំណុច ក នៃព្រះរាជក្រឹត្យលេខ នស/រកត/១១១១/១០៣៤ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១១ ត្រូវទុកជានិរាករណ៍ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៣. ១១១២. ១១៤៩

លេខៈ ១៩ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១២
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១១

សយ សុខា

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:**.....០១.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ចេញពីផែនទីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងការចាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋនូវផ្ទៃដី ដែលបានដកហូតដោយដីការរបស់សាលាខេត្តក្រចេះកាលពីឆ្នាំ ២០០៦

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ ៖**

ត្រូវបានកាត់ចេញពីដែនទីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ឆ្នាំ២០០២ និងចាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីចំនួន ២.៨៤៨ ហ.ត (ពីរពាន់ប្រាំបីរយសែសិបប្រាំបីហិកតា) ស្ថិតនៅក្នុងឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ ដែលសាលាខេត្តក្រចេះបានចេញដីកាដកហូតលេខ ៣២ អគខ.ក្រច ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦ និងដីកាលេខ ៣០ អគខ.ក្រច ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៦ ក្នុងនោះផ្ទៃដីចំនួន ១.២៤២ហ.ត (មួយពាន់ពីររយសែសិបពីរហិកតា) ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៧៦ ចន្លោះពីភូមិជើងឃ្លេ ឃុំ២ធ្នូ ស្រុកស្នួល (UTM 661005-1331987) ទៅព្រែកជីមាំង (UTM 664189-1335921) និងចំនួន ១.៦០៦ហ.ត (មួយពាន់ប្រាំមួយរយប្រាំមួយហិកតា) ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៧៤ ចន្លោះពីភូមិជើងឃ្លេ ស្រុកស្នួល ខេត្តក្រចេះ ទៅដល់ព្រំដែនកម្ពុជា-វៀតណាម (UTM 659307-1332406) ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២ ៖**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា ១ ជូនគណៈអភិបាលខេត្តក្រចេះ ដើម្បីគ្រប់គ្រង បែងចែក និងប្រើប្រាស់ដី តាមករណីនៃការកាន់កាប់ និងប្រើប្រាស់ដីជាក់ស្តែងរបស់ប្រជាពលរដ្ឋ និងគម្រោងប្លង់អភិវឌ្ឍន៍តំបន់ព្រំដែនរបស់ខេត្ត ហើយនិងផែនការប្រើប្រាស់ដីធ្លីស្រុកស្នួល។

**មាត្រា ៣ ៖**

ខេត្តត្រូវបង្កើតក្រុមការងារអន្តរស្ថាប័នមួយ ដោយមានជំនួយបច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បី (១)ពិនិត្យ និងធ្វើបច្ចុប្បន្នកម្មនូវបញ្ជីឈ្មោះអ្នកកាន់កាប់ដីជាក់ស្តែងឡើងវិញឲ្យបានច្បាស់លាស់ (២)ធ្វើបច្ចុប្បន្នកម្មនូវគម្រោងប្លង់អភិវឌ្ឍន៍តំបន់ព្រំដែនរបស់ខេត្តដែលបានសិក្សារៀបចំពីឆ្នាំ១៩៩៦ និងឆ្នាំ២០០០ នោះឡើងវិញ និងត្រូវរៀបចំផែនការប្រើប្រាស់ដីធ្លីស្រុកស្នួលឲ្យបានច្បាស់លាស់ជាមុន លើមូលដ្ឋាននៃនីតិវិធីដែលមានចែងក្នុងអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ មុននឹងដំណើរការបែងចែកដីជាក់ស្តែង។

**មាត្រា ៤ ៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៥ ៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ


COORDINATE SYSTEM
Projection: UTM
Zone: 48N
Horizontal Datum: WGS84
Spheroid: WGS84
Unit: Meter
0 1,000 2,000 4,000
Meters

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ០៧.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨៣៥ ហិកតា និង ១៨០០ម៉ែត្រក្រឡា ស្ថិតនៅក្នុង ព្រៃការពារ និងអភិរក្ស ជីវចំរុះ "សីមា" ក្នុងភូមិអណ្តូងក្រឡឹង ឃុំសែនមនោរម្យ ស្រុកអូរាំង ខេត្តមណ្ឌលគីរី

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រតក/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១:**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៨៣៥,១៨ ហិកតា (ប្រាំបីរយសាមសិបប្រាំហិកតា និងមួយពាន់ប្រាំបីរយម៉ែត្រក្រឡា ) ស្ថិតក្នុងភូមិអណ្តូងក្រឡឹង ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគីរី ដើម្បីចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចពួង ដូចមានក្នុងផែនទី និងនិយាមកាចុះលេខ ៩៧២ ដនស ចុះថ្ងៃទី១៣ ខែ តុលា ឆ្នាំ ២០១១ ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងចុះលេខ ៨៣៨៩ / ៩៥០កសក. នផ. ផក ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១១ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា២:**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់ក្រសួងស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគីរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ៤
- -រាជកិច្ច
- -ឯកសារកាលប្បវត្តិ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

* * * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

### ស ម្រេ ច

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិ ឯកឧត្តម **ហេង ហួត** ពីអនុមន្ត្រីថ្នាក់លេខ ៤ ទៅវរមន្ត្រីថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងបរិស្ថាន។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០៧ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ,

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៦រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធានចូលរួមជួយកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ អោយមានការរីកចម្រើនកន្លងមក ដូចមានរាយនាមខាងក្រោម៖

| | |
|---|---|
| ១-បណ្ឌិត **ឯក ឆេងហួត** | សប្បុរសជនរាជធានីភ្នំពេញ ថវិកា១២.០០០ដុល្លាអាមេរិក |
| ២-លោកជំទាវ **អ៊ុន ឌួចលី សៀង ណាំ** | សប្បុរសជនខេត្តសៀមរាប ថវិកា១២.១៣០ដុល្លាអាមេរិក |
| ៣-លោក **ខឿង ប្រយុទ្ធ** | សប្បុរសជនរាជធានីភ្នំពេញ ថវិកា១២.០០០ដុល្លាអាមេរិក |
| ៤-លោកស្រី **ខឿង ចាន់ណា** | សប្បុរសជនរាជធានីភ្នំពេញ ថវិកា១១.៨៥០ដុល្លាអាមេរិក |
| ៥-លោក **យន់ លីនណេ** | សប្បុរសជនខេត្តសៀមរាប ថវិកា១០.៦៥០ដុល្លាអាមេរិក |
| ៦-លោក **ម៉ឹន វ៉ៃ** | សប្បុរសជនរាជធានីភ្នំពេញ ថវិកា១០.០០០ដុល្លាអាមេរិក |
| ៧-ឧត្តមសេនីយ៍ឯក **ផាន់ សាមន្លា**អត្ត.០០១១៨៨ | ទីប្រឹក្សាក្រសួងការពារជាតិថវិកា១១.៦០០ដុល្លាអាមេរិក |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ០៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងសប្បុរសជន ចំនួន ៥៨រូប ដែលមានគុណបំណាច់ និងស្នាដៃល្អ ដោយបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមកសាង អភិវឌ្ឍន៍ប្រទេសជាតិ ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ នាពេលកន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

| | |
|---|---|
| ០១-លោកជំទាវ **សោម សុភារី** | ទីប្រឹក្សាផ្ទាល់សម្តេចអគ្គធម្មពោធិសាល **ជា ស៊ីម** |
| ០២-ឯកឧត្តម **លី សុខគីម** | ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ថវិកា៦៥.២០០ដុល្លាអាមេរិក |
| ០៣-វរសេនីយ៍ឯក **ច្រឹង ផល្លី** | អត្ត.០២០៣៥ ស្នងការរងនគរបាលខេត្តក្រចេះ |
| ០៤-លោក **ហេង រតនា** | សប្បុរសជនរាជធានីភ្នំពេញ |
| ០៥-អនុសេនីយ៍ឯក **សី ម៉េងឈុន** | អត្ត.១៨៦៧៣ អធិការរងនគរបាលស្រុកព្រែកប្រសព្វ ស្នងការរងនគរបាលខេត្តក្រចេះ |
| ០៦-លោក **ឃិន សុផល** | សប្បុរសជនខេត្តរតនគីរី |
| ០៧-លោកវេជ្ជបណ្ឌិត **ហែម រ៉ាឌី** | សប្បុរសជនរាជធានីភ្នំពេញ |
| ០៨-លោកស្រី **សេង ចាន់ធូ** | អភិបាលរងស្រុកកូនមុំ ខេត្តរតនគីរី |
| ០៩-លោក **ជា ដែប** | អធិការ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា |
| ១០-លោកស្រី **ម៉ុក សុម៉ាលី** | សប្បុរសជនខេត្តស្វាយរៀង |
| ១១-លោកស្រី **កែវ សុគន្ធា** | សប្បុរសជនខេត្តស្វាយរៀង |
| ១២-លោកស្រី **ហុក និព្វកេសា** | មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា |
| ១៣-លោក **សន សុវណ្ណា** | អនុប្រធានផ្នែកបែបបទអគ្គនាយកដ្ឋានរដ្ឋាករស្វ័យយ័តរាជធានីភ្នំពេញ |

១៤-ឯកឧត្តម **ពេជ្រ កៅ** ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ថវិកា៨៧.៦៥០ដុល្លាអាមេរិក
១៥-ឧត្តមសេនីយ៍ត្រី **ហ៊ីង រស្មី** អត្ត. ០៥០៤២ ប្រធានអង្គរក្សសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន**
១៦-ឧត្តមសេនីយ៍ត្រី **ភាន់ ផា** អត្ត. ០៥០៤៣ អនុប្រធានអង្គរក្សសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន**
១៧-ឧត្តមសេនីយ៍ត្រី **មាស ឈុនឡេង** អត្ត. ០៤៧២៦ ជាអ្នកបើកបររថយន្តជូនសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន**

**ខ-មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

០១-វរសេនីយ៍ត្រី **ថន ធុន** អត្ត.០១៨៥០១ នាយការិយាល័យហិរញ្ញវត្ថុខេត្តរតនគិរី
០២-វរសេនីយ៍ត្រី **ម៉ី ខៀវ** អត្ត.០០៩៧៦៩ នាយការិយាល័យទី៤ខេត្តរតនគិរី
០៣-លោកស្រី **សៀក មាលា** បុគ្គលិកអង្គការអោហ្វស៊ីប
០៤-លោក **ឆន់ សុខ** អនុប្រធានផែនការ និងគណនេយ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
០៥-លោក **ចាន់ សារឿន** សប្បុរសជនខេត្តស្វាយរៀង
០៦-អនុសេនីយ៍ឯក **អ៊ិន សុផានណារិទ្ធ** អត្តលេខៈ០៨៦៦២ មន្ត្រីនគរបាលក្រសួងមហាផ្ទៃ
០៧-អនុសេនីយ៍ត្រី **អាន សំអុល** អត្តលេខៈ៦៣៣៩៩ មន្ត្រីនគរបាលក្រសួងមហាផ្ទៃ
០៨-លោក **យ៉ែម ចំរើន** សប្បុរសជនរាជធានីភ្នំពេញ
០៩-លោកស្រី **ស៊ុត សុគន្ធធារី** អនុប្រធានរតនាគារាជធានីភ្នំពេញ
១០-លោក **សោម សុភ័ណ្ណារ៉ា** សប្បុរសជនខេត្តរតនគិរី
១១-លោក **ឈុន ហុក** ប្រធាននាយកដ្ឋានរដ្ឋបាល ក្រសួងអប់រំ យុវជន និងកីឡា
១២-លោក **អែម សាលី** សប្បុរសជនរាជធានីភ្នំពេញ
១៣-លោកស្រី **តាន់ ណារ៉ា** សប្បុរសជនខេត្តក្រចេះ
១៤-លោកស្រី **យ៉េន ចាន់ណា** សប្បុរសជនខេត្តក្រចេះ
១៥-សាស្ត្រាចារ្យ **ទីន សុខខេង** មន្ត្រីមន្ទីរអប់រំ យុវជន និងកីឡាខេត្តក្រចេះ
១៦-សាស្ត្រាចារ្យ **យូ គីមឡាយ** ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុកចិត្របុរី ខេត្តក្រចេះ
១៧-លោក **ឌុច អ៊ិច** សប្បុរសជនខេត្តក្រចេះ
១៨-លោកស្រី **ផន ចន្ថា** អនុប្រធានការិយាល័យពាណិជ្ជកម្ម មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង
១៩-លោក **សៀង ឡុង** សប្បុរសជនខេត្តក្រចេះ

**គ-មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់អស្សឫទ្ធិ**

០១-លោកស្រី **ចាន់ ស៊ីណាត** សប្បុរសជនរាជធានីភ្នំពេញ
០២-លោកស្រី **ជា ស៊ីន្ធួន** សប្បុរសជនរាជធានីភ្នំពេញ
០៣-លោកស្រី **នាង សុភរី** មន្ត្រីវិទ្យាស្ថានកាសាបរទេស
០៤-លោកស្រី **ឆឹម ចណ្ណារី** មន្ត្រីវិទ្យាស្ថានកាសាបរទេស
០៥-លោកស្រី **ខុន សារី** មន្ត្រីវិទ្យាស្ថានកាសាបរទេស
០៦-លោកស្រី **ថ្លាង ចាន់ទី** មន្ត្រីវិទ្យាស្ថានកាសាបរទេស
០៧-លោកស្រី **និត្យ ចាន់ទី** មន្ត្រីវិទ្យាស្ថានកាសាបរទេស
០៨-លោក **ឃ្លាំង ចណ្ណថន** មន្ត្រីវិទ្យាស្ថានកាសាបរទេស
០៩-លោក **គឹម ភន** មន្ត្រីវិទ្យាស្ថានកាសាបរទេស
១០-លោក **ភ្លោប សាវី** មន្ត្រីវិទ្យាស្ថានកាសាបរទេស
១១-លោក **ស្វាយ សុខេង** មន្ត្រីវិទ្យាស្ថានកាសាបរទេស
១២-លោក **ឈុន យ៉េន** មន្ត្រីវិទ្យាស្ថានកាសាបរទេស
១៣-លោក **អ៊ុក សារឿន** មន្ត្រីវិទ្យាស្ថានកាសាបរទេស
១៤-លោក **ហង់ ពៅ** មន្ត្រីវិទ្យាស្ថានកាសាបរទេស
១៥-លោក **មាស សាឯម** មន្ត្រីវិទ្យាស្ថានកាសាបរទេស
១៦-លោក **ថាច់ សុវណ្ណា** មន្ត្រីវិទ្យាស្ថានកាសាបរទេស

១៧-លោក **សុន ពិសិដ្ឋ** មន្ត្រីវិទ្យាស្ថានភាសាបរទេស
១៨-អនុសេនីយ៍ឯក **យូ សំអុន** អគ្គលេខ០៥២៤១៥ មេបញ្ជាការរងការពារព្រំដែនលេខ១០២ខេត្តរតនគិរី
១៩-លោក **ជា ស័ក្តរ៉ា** សប្បុរសជនរាជធានីភ្នំពេញ
២០-លោក **ជា ស័ក្តណា** សប្បុរសជនរាជធានីភ្នំពេញ
២១-លោក **ហុក និព្វរុត្ថា** សប្បុរសជនរាជធានីភ្នំពេញ
២២-អនុសេនីយ៍ទោ **អ៊ុន សុភ័ស្ត** អត្ត. ៦៤៦៥៣ មន្ត្រីនគរបាលក្រសួងមហាផ្ទៃ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៤.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ៧៤រូប ដែលមានស្នាដៃល្អក្នុងការចូលរួមកសាង អភិវឌ្ឍន៍ ប្រទេសជាតិ ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ នាពេលកន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយ មាសការងារ**

០១-លោកគ្រូពេទ្យ **កេត ឌីម៉ង់** ប្រធានមណ្ឌលសុខភាព ស្រុកអណ្តូងមាស ខេត្តរតនគីរី

០២-លោកគ្រូពេទ្យ **ហេង ស្រលុក** អនុប្រធានមណ្ឌលសុខភាព ស្រុកអណ្តូងមាស ខេត្តរតនគីរី

០៣-វរសេនីយ៍ត្រី **សៀ ធីន** អត្តលេខ០៩៤៩០០ អនុប្រធានមន្ទីរភស្តុភារ និងបច្ចេកទេស កងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ

០៤-វរសេនីយ៍ទោ **ម៉ក់ យ៉ាន** អត្តលេខ០៨០៧៨៩ មន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន ក្រសួងការពារជាតិ

០៥-អនុសេនីយ៍ឯក **សេង សំរេច** អត្តលេខ ០៩៣៤២៨ ជំនួយការការិយាល័យបុគ្គលិក អគ្គបញ្ជាការដ្ឋានក្រសួងការពារជាតិ

០៦-អនុសេនីយ៍ត្រី **សៀ គីរីរាជ** អត្តលេខ ១៥០៣៤៣ នាយអាវុធហត្ថ កងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ

០៧-វរសេនីយ៍ត្រី **អ៊ិន បូរិន** អត្តលេខ ០៤៨៦៤៣ នាយការិយាល័យទី២ទ័ពជើងគោក ស្នាក់ការខេត្តឧត្តរមានជ័យ

០៨-លោក **សោម សាយធូវិចិត្រ** សប្បុរសជនរាជធានីភ្នំពេញ

០៩-លោក **ឆោម ឌុទ្ធី** ជំនួយការមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង

១០-លោក **មាស ឌុទ្ធី** សមាជិកក្រុមការងារចុះជួយខេត្តព្រៃវែង

១១-លោក **សោម ម៉ានី** សមាជិកក្រុមការងារចុះជួយខេត្តព្រៃវែង

១២-លោក **ឡាយ ពន្លឺក** ប្រធានប្រតិបត្តិការគម្រោង អង្គការស៊ីម៉ាក់

១៣-លោកស្រីវេជ្ជបណ្ឌិត **ម៉ា លី** ប្រធានផ្នែកសុខភាព អង្គការអាហ្វេស៊ីបកម្ពុជា

១៤-លោក **សួង ជា** ប្រធានក្រុមការងារដោះមីន២០២ មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា

១៥-លោក **ស្តើង សារុន** ប្រធានគណៈកម្មការវត្តភ្នំស្វាយ

១៦-ព្រិន្ទបាលឯក **គេង គីរុណា** អត្ត.០៩៤៩១០ ជំនួយការកងអាវុធហត្ថ ខេត្តបន្ទាយមានជ័យ

១៧-លោក **សោម ចំរើន** សប្បុរសជនខេត្តសៀមរាប

១៨-អ្នកស្រី អ៊ុំ សុតីយ៉ាន មន្ត្រីគយ និងរដ្ឋាករស្នាក់ការត្រពាំងផ្លុង ខេត្តកំពង់ចាម
១៩-អនុសេនីយ៍ឯក ស៊ិន តារាហេង អត្តលេខ៣១០៥៩ មន្ត្រីនគរបាលក្រសួងមហាផ្ទៃ
២០-លោកទូច សំអឿន សមាជិកក្រុមការងារចុះជួយខេត្តព្រៃវែង
២១-លោក ហេង ពិសិដ្ឋ សប្បុរសជនខេត្តបន្ទាយមានជ័យ
២២-លោក អៀង វណ្ណៈ សប្បុរសជនខេត្តបន្ទាយមានជ័យ
**២៣- លោក ស៊ីន ស៊ីទុច សប្បុរសជនរាជធានីភ្នំពេញ**
**២៤- លោក ឈុប តាំងអួន មន្ត្រីមន្ទីរសុខាភិបាលខេត្តរតនគិរី**
២៥-លោកគ្រូ តែន គីហ៊ន សាស្ត្រាចារ្យវិទ្យាល័យបឹងត្របែក
២៦-លោក ផែន ម៉ាប់ សប្បុរសជនខេត្តបន្ទាយមានជ័យ
២៧-លោក ប៊ី ម៉ុនហ៊ាង នាយករងរដ្ឋបាលសាលាក្រុងបានលុង ខេត្តរតនគិរី
២៨-នាយចំណង់ ព្រាប ធឿត អត្តលេខ០៥៤៤២៦ ជំនួយការស៊ើបការណ៍កងពលតូចលេខ៥១
២៩-លោក សំ ចិត្រា សប្បុរសជនខេត្តបាត់ដំបង
៣០-លោក ឆាន ឈឿន សប្បុរសជនខេត្តបន្ទាយមានជ័យ
៣១-លោកស្រី លឹម សុខជា ប្រធានគម្រោង កាកបាទក្រហមកម្ពុជា
៣២-លោក គីម បញ្ញា ប្រធានគម្រោង កាកបាទក្រហមកម្ពុជា
៣៣-លោក សំ សុភ័ក្ត្រ មន្ត្រីនាយកដ្ឋានឧត្តមសិក្សា
៣៤-លោក ហ៊ាង សុទ្ធាយុត្តិ បុគ្គលិកធនាគារពិភពលោក
៣៥-អនុសេនីយ៍ឯក ម៉ៅ សុគុណា អត្តលេខ៥៤៦៤៦ ប្រធានផ្នែក ការិយាល័យប្រឆាំងបទល្មើសសេដ្ឋកិច្ច ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
៣៦-អនុសេនីយ៍ឯក សៅ រ៉ា អត្តលេខ០៩៨៦៥ អនុប្រធានផ្នែក ការិ.ប្រឆាំងបទល្មើសសេដ្ឋកិច្ច ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
៣៧-អនុសេនីយ៍ឯក ប៉ាន់ ឡៃយៀងអត្តលេខ១១៧២៩ នាយរងការិយាល័យអន្តោប្រវេសន៍ ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង
៣៨-អនុសេនីយ៍ឯក ហ៊ុល វាសនាអត្តលេខ១៩៦៨៤ អធិការរងនគរបាលក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
៣៩-ព្រិន្ទបាលឯក អ៊ុល ចាន់ថា អត្តលេខ៤៥៨៥៩ នាយរងផ្នែក ការិយាល័យចរាចរណ៍ផ្លូវទឹក ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង
៤០-ព្រិន្ទបាលឯក យឹម បញ្ញា អត្តលេខ៦៣៥៧៤ មន្ត្រី ការិយាល័យសណ្តាប់ធ្នាប់ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង
៤១-វរសេនីយ៍ត្រី លុយ ឌីណា អត្តលេខ០៨៩៦៤ នាយការិយាល័យបង្ការ ពន្លត់អគ្គីភ័យ ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង
៤២-ព្រិន្ទបាលឯក ចាន់ សារិទ្ធ អត្តលេខ៤៦០១៩ នាយរងផ្នែក ការិយាល័យចរាចរណ៍ផ្លូវទឹក ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង
៤៣-លោកស្រីអនុសេនីយ៍ទោ សុខ បូរី អត្តលេខ៣១៨២៤ មន្ត្រីការិយាល័យផែនការ អគ្គនាយកដ្ឋានកស្តុភារហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ
៤៤-លោក ផន សុផល មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា
៤៥-លោក កែវ បូរី មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា
៤៦-លោក យ៉េង ហួន ប្រធានភូមិធ្លកជ្រុំ ក្រុងសៀមរាម ខេត្តសៀមរាប
៤៧-អនុសេនីយ៍ត្រី លីវ នាម អត្តលេខ០៥២៣៥១ មេបញ្ជាការកងអនុសេនាតូចស៊ើបការណ៍ វរសេនាតូចការពារព្រំដែនលេខ១០២
៤៨-អនុសេនីយ៍ត្រី អៀង សុះយៀងអត្តលេខ០៨១៥៥០ មេបញ្ជាការកងអនុសេនាតូចទី៤ វរសេនាតូចការពារព្រំដែនលេខ១០២
៤៩-អនុសេនីយ៍ត្រី ឡុង សុប៊ុន អត្តលេខ០៥២៤១៨ មេបញ្ជាការរងកងអនុសេនាធំទី១ វរសេនាតូចការពារព្រំដែនលេខ១០២
៥០-អនុសេនីយ៍ត្រី កែវ ម៉ុនធឿនអត្តលេខ០៥២៤១៧ មេបញ្ជាការរងកងអនុសេនាធំទី២ វរសេនាតូចការពារព្រំដែនលេខ១០២
៥១-អនុសេនីយ៍ត្រី យិន យឿន អត្តលេខ០៥២៤២២ មេបញ្ជាការរងកងអនុសេនាធំទី២ វរសេនាតូចការពារព្រំដែនលេខ១០២
៥២-អនុសេនីយ៍ត្រី លី សៀងហួតអត្តលេខ១៤៩០៤០ មេបញ្ជាការរងកងអនុសេនាធំទី១ វរសេនាតូចការពារព្រំដែនលេខ១០២
៥៣-នាយចំណង់ សុខ ចំណាន អត្តលេខ០៧៣០១៨ មេបញ្ជាការកងអនុសេនាតូចទី២ វរសេនាតូចការពារព្រំដែនលេខ១០២
៥៤-ព្រិន្ទបាលឯក លៀម ណារ៉ុត អត្តលេខ១៤៩២០៣ យោធិនកងអនុសេនាធំទី១ វរសេនាតូចការពារព្រំដែនលេខ១០២
៥៥-លោក ជា ឆេង អនុប្រធានភូមិក្បាលទំនប់១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ
៥៦-លោក ជិន សុខ សប្បុរសជនខេត្តកំពង់ចាម
៥៧-លោក ស្លាត គីមសុំ សប្បុរសជនខេត្តកំពង់ចាម
៥៨-លោកស្រី ជេត ម៉ារី សប្បុរសជនរាជធានីភ្នំពេញ
៥៩-លោក យឹម ចន្ទី សប្បុរសជនរាជធានីភ្នំពេញ
៦០-លោក លី ម៉ុនហេង សប្បុរសជនរាជធានីភ្នំពេញ
៦១-អនុសេនីយ៍ត្រី ម៉ុន ណារ៉ា អត្តលេខៈ៦៦០១៨ មន្ត្រីនគរបាលស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ

៦២-អនុសេនីយ៍ឯក **ឃ្លោក ច័ន្ទតារា** អត្តលេខ:០២២២៨៤៤ មន្ត្រីកងរាជអាវុធហត្ថខ័ណ្ឌដូនពេញ
៦៣-លោក **គិច ម៉ារឌី** សប្បុរសជនរាជធានីភ្នំពេញ
៦៤-លោក **ឆន វណ្ណៈ** មន្ត្រីអគ្គលេខាធិការរដ្ឋសភា
៦៥-អនុសេនីយ៍ឯក **គិច ពៅ** អត្តលេខ:៣១៧៩០ មន្ត្រីនគរបាលក្រសួងមហាផ្ទៃ
៦៦-វរសេនីយ៍ត្រី **អ៊ុំ សំអាង** អត្តលេខ៣៤០៦០ មន្ត្រីក្រសួងមហាផ្ទៃ
៦៧-អនុសេនីយ៍ត្រី **ស៊ឹម ហេង** អត្តលេខ៣៩៣៤៥ មន្ត្រីក្រសួងមហាផ្ទៃ
៦៨-អនុសេនីយ៍ទោ **ម៉ឺន ម៉ន** អត្តលេខ៣៩០៩៣ មន្ត្រីក្រសួងមហាផ្ទៃ

**ខ-មេដាយ ប្រាក់ការងារ**

០១-លោក **កង ចន្ថារិទ្ធ** អធិការ នៃអគ្គាធិការដ្ឋានរដ្ឋសភា
០២-លោកស្រី **កុសល ពន្យវឌ្ឍនី** មន្ត្រីអគ្គលេខាធិការរដ្ឋសភា
០៣-អនុសេនីយ៍ទោ **លឹម សុខលី** អត្តលេខ៤០២២៤ មន្ត្រីការិយាល័យប្រឆាំងបទល្មើសសេដ្ឋកិច្ច ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
០៤-អនុសេនីយ៍ត្រី **អូត ស៊ីផុន្ថា** អត្តលេខ៥៧២៨២ មន្ត្រីការិយាល័យប្រឆាំងបទល្មើសសេដ្ឋកិច្ច ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
០៥-អនុសេនីយ៍ត្រី **អ៊ឹម សោភា** អត្តលេខ៥៧៤៣៣ មន្ត្រីការិយាល័យប្រឆាំងបទល្មើសសេដ្ឋកិច្ច ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
០៦-អនុសេនីយ៍ទោ **ហេង បូរិន** អត្តលេខ៥៤៦៥៨ មន្ត្រីការិយាល័យប្រឆាំងបទល្មើសសេដ្ឋកិច្ច ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងសមាសភាពគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៣ ស្តីពីការបង្កើតគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

# សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងសមាសភាពគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ដូចខាងក្រោម៖

| | | |
|---|---|---|
| ១ -ឯកឧត្តម | **សំ សុខផល** | ប្រធាន |
| ២ -ឯកឧត្តម | **ស៊ិន សំណាង** | អនុប្រធាន |
| ៣ -ឯកឧត្តម | **សេង ស៊ីវុត្ថា** | សមាជិក |
| ៤ -ឯកឧត្តម | **ឡាំ ជា** | សមាជិក |
| ៥ -ឯកឧត្តម | **ព្រុំ ម៉ល់** | សមាជិក |
| ៦ -ឯកឧត្តម | **រស់ ចន្ត្រាបុត្រ** | សមាជិក |
| ៧ -ឯកឧត្តម | **អ៊ីង ច័ន** | សមាជិក |
| ៨ -ឯកឧត្តម | **ឈន អឿម** | សមាជិក |
| ៩ -ឯកឧត្តម | **ឆយ អូន** | សមាជិក |
| ១០-ឯកឧត្តម | **ច័ន្ទ សំណាញ** | សមាជិក |

១១-ឯកឧត្តម **សឹង ផុស** សមាជិក
១២-ឯកឧត្តម **សូ មុយឃៀង** សមាជិក
១៣-លោកជំទាវ **ខ្លូត ធីតា** សមាជិក
១៤-ឯកឧត្តម **ម៉ុញ សារី** សមាជិក
១៥-ឯកឧត្តម **ម៉ៅ សុភ្ជន** សមាជិក
១៦-ឯកឧត្តម **ស៊ុំ ឈុំប៊ុន** សមាជិក
១៧-ឯកឧត្តម **ប៊ុន ហុន** សមាជិក
១៨-ឯកឧត្តម **ផៃ សុខខេង** សមាជិក
១៩-ឯកឧត្តម **លី ច័ន្ទតុលា** សមាជិក
២០-ឯកឧត្តម **ឌួង ឧត្តម** សមាជិក
២១-ឯកឧត្តម **សំ រិទ្ធី** សមាជិក
២២-ឯកឧត្តម **ស្រ៊ុន ធីរិទ្ធ** សមាជិក
២៣-ឯកឧត្តម **ស៊ា ម៉ៅ** សមាជិក
២៤-ឯកឧត្តម **ឃាង សេង** សមាជិក
២៥-ឯកឧត្តម **ផូច សំភី** សមាជិក
២៦-លោកស្រី **ចាំង ស៊ីណាត** សមាជិក
២៧-លោក **ថាច់ សែម** សមាជិក
២៨-លោកស្រី **ហ្វូត លីដា** សមាជិក។

**មាត្រា ២** : ត្រូវបានតែងតាំង ជាទីប្រឹក្សាគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ដូចខាងក្រោម៖
១-ឯកឧត្តម **ហេង វង្សប៊ុនឆាត**
២-ឯកឧត្តម **ហេង ឌី**។

**មាត្រា ៣** : អនុក្រឹត្យលេខ១២៧៧.អនក្រ.តត ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

